រដ្ឋប្រហារ លាក់មុខ

លោក ហ៊ុន សែន គាត់ និយាយ ដដែលៗ ថា បើ គណបក្សប្រជាជនកម្ពុជា ចាញ់ឆ្នោត នឹងមាន សង្គ្រាមកើតឡើង។ សំដីហ្នេះ វា ជា ការពិត បើ លោក ហ៊ុន សែន មាន មាន: ចង់ការពារ អំណាច ក្នុងតម្លៃ ប៉ុនណាក៏ដោយ នុះត្រូវ គាត់ ធ្វើ រដ្ឋប្រហារ ព្រោះ ច្បាប់រដ្ឋធម្មនុញ្ញ មិនអនុញ្ញាត ១ គាត់ បន្ត កាន់អំណាច បើ គណបក្ស របស់គាត់ ចាញ់ឆ្នោត។ តម្លៃ ច្បាប់នេះ ជា ការ ពិត តែមួយ សំរាប់ ប្រជាពលរដ្ឋខ្មែរ។ អាស្រ័យហេតុនេះ បាន ជា លោក ហ៊ុន សែន តម្រូវ១ ម្ចាស់ឆ្នោត ជ្រើសរើស រវាង ការ ពិត របស់គាត់ និង ប្រជាពលរដ្ឋ។ លោក ហ៊ុន សែន គាត់ វាយ តម្លៃ អំណាច របស់គាត់ ស្មើនឹង សន្ទិភាព ដែល ជា ទស្សន: អប្បច្ចុយភាព[1] ព្រោះ សន្ទិភាព ជា តម្លៃសាកល ពុំអាចអ្នកណា មួយ យកវាមកធ្វើជា កម្មសិទ្ធិផ្ទាល់បាននោះឡើយ។ ឯចំណែក សង្គ្រាម វិញ វា មាន ខ្លឹមសារ ជា អំពើហិង្សា ទោះបី ហិង្សានោះ មាន ធម្មជាតិ យ៉ាងណាក្តី គឺថា ទោះបី វា ស្របច្បាប់ ក៏វា នៅ តែជា អំពើហិង្សា តែ បើ វា មិនស្របច្បាប់ គឺ គេ ទុក វា ជា បទ ឧក្រិដ្ឋ។ មួយវិញទៀត គេដឹងថា សន្ទិភាព មាន នៅ ស្រុកខ្មែរ សព្វថ្ងៃ វា ជា សន្ទិភាព កើតចេញពី ច្បាប់ គឺ កិច្ចព្រមព្រៀង

[1] ទស្សន: អប្បច្ចុយភាព ; concept illogique ; ទស្សន:ភ្ជានទំនងដ។

សន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ មិនដូច ការយល់ឃើញ របស់ លោក ហ៊ុន សែន និង បក្សពួក ថា ជា សន្តិភាព កើតចេញ ពី ឈាមតស៊ូ របស់គណបក្សប្រជាជនកម្ពុជា ដូច្នេះ បក្ស ជា ម្ចាស់ នៃ សន្តិភាព និងជា ម្ចាស់អំណាចបក្សអស់មួយជីវិត។ ដូច្នេះ លទ្ធផល នៃ ការបោះឆ្នោត ដែល លោក ហ៊ុន សែន គោរព គឺ ជ័យជំនះ នៃ គណបក្សប្រជាជនកម្ពុជា ពុំនោះសោត គាត់ ត្រូវតែធ្វើ សង្គ្រាម។ នៅក្នុង កំនិតនេះ លោក ហ៊ុន សែន បានព្រមាន ជាមុន ដល់ ក្រប់ គណបក្សនយោបាយ ដែល ចូលរួមបោះឆ្នោត ថា ត្រូវតែ សុខចិត្ត ចាញ់ជាដាច់ខាត ពុំនោះ សោត នឹងត្រូវទទួលទោស តាម អយ្យការសឹក ព្រោះ ការ ប្រកាស នៃ ជ័យជំនះ របស់ លោក ហ៊ុន សែន វាជា ច្បាប់ សំរាប់ ក្រប់គណបក្សនយោបាយ ដែលក្លាយទៅជា ក្រុមប្រតិកម្ម[2] ប្ដូរ ឧត្តមគតិ ទៅតាម អធិបញ្ញា[3] ហ៊ុន សែន។ ឧត្ថាស[4] នៃ អំណាច ហ៊ុន សែន វា មានកំរិតមួយ ធ្វើអោយ លទ្ធិប្រជាធិបតេយ្យ នៅ ស្រុកខ្មែរ ក្លាយ ជា មយ្យោបាយ អសុចរិត របស់ពួកអ្នកកាន់ អំណាច សំរាប់តែ ពោលអះអាង ថា អំណាចពួកខ្លួន ជា អំណាចស្របច្បាប់។ ពាក្យបោះឆ្នោត នៅស្រុកខ្មែរសព្វថ្ងៃ មាន ទ្វេនន័យ។ មួយ ជា សេចក្ដីសង្ឃឹម ជាយុត្តិកម្ម[5] នៃប្រជាពលរដ្ឋ ថានឹង អាចមាន បំលាស់ប្ដូរ អ្នកដឹកនាំ តាមសន្តិវិធី ព្រោះ

---

[2] ក្រុមប្រតិកម្ម ; groupe de réaction។
[3]អធិបញ្ញា; ការបង្ហាប់ដោយដាច់ខាត ; injonction។
[4]ឧត្ថាស; សេចក្ដីខ្លាច ; frayeur។
[5] សេចក្ដីសង្ឃឹមមជាយុត្តិកម្ម គឺជាសេចក្ដីសង្ឃឹមមានភស្តុតាង; espoir justifié.

ការបោះឆ្នោត ជា សិទ្ធិ សារវន្ត របស់ពលរដ្ឋ ដែល ជា ម្ចាស់ នៃ អំណាច; នយទី២ គឺ ជា ការបោកប្រាស សំរាប់ គណបក្សកាន់ អំណាច អាចរក្សាអំណាច និង គណបក្សប្រឆាំង អាចប្រគោង បុព្វសិទ្ធិ នៅក្នុងប្រព័ន្ធនយោបាយបច្ចុប្បន្ន ក្នុងនោះ ពួកអ្នក កាន់អំណាច និង អ្នកប្រឆាំង ចំណុះចុះចូល គប់គិតគ្នា ដើម្បី រក្សា ផលប្រយោជន៍រួម ដែលជា ប្រយោជន៍ ត្រូវតែចែក ជាមួយ ឃួន ព្រោះ ឃួន មាន ហ៊ុនអំណាច នៅស្រុកខ្មែរ។ នៅក្នុងនយ ទី២ នេះហើយ ដែល លោក ហ៊ុន សែន យកពាក្យសង្គ្រាម ដែល ជា ពាក្យ រដ្ឋប្រហារ លាក់មុខ មក បោកប្រាស់ ជាលេស សំរាប់ គំរាម ដល់ អ្នកបោះឆ្នោត។ ការបោកប្រាសនេះ គេអាចទុក បានជា រិច្ចេទកម្មប្រឆាំងនឹង **សេចក្ដីពិត**, **កុសល** និង **ច្បាប់**។ តែ បើ អ្នកបោះឆ្នោត ជា មនុស្ស មាន សេចក្ដី ក្លាហាន និង មាន ភាពមោះមុត ការពារ ឆន្ទៈ របស់ខ្លួន ភ្ជានក្រហែង, ឧត្តមមនុស្សនោះ ជា វិធានការ គ្រប់បែបយ៉ាង សំរាប់ ដោះ ស្រាយ គ្រប់បញ្ហា[6]។ ពាក្យសង្គ្រាម ជា ពាក្យ ញ្ជះញ្ជង់ និង កំហែង សំរាប់តែ បំភិតបំភ័យ ដល់ មហាជន តែ លោក ហ៊ុន សែន មិនអាច យក មធ្យោបាយ នៃ សង្គ្រាម សំរាប់ សម្លាប់ ប្រជាជនច្រើនកុះការ ដើបប្រឆាំងនឹង អំណាចផ្តាច់ការ បាន នោះឡើយ; ពិតប្រាកដណាស់ថា លោក ហ៊ុនសែន អាចបញ្ជា អោយបំរើខ្លួន សម្លាប់ អ្នកប្រឆាំងគាត់ ដប់ម្នែនាក់បាន តែ

[6] មនុស្ស ជា វិធានការ គ្រប់បែបយ៉ាង សំរាប់ដោះស្រាយបញ្ហា ; l'homme est la mesure de toutes choses។

រដ្ឋប្រហារ លាក់មុខ

សម្លាប់ អ្នកប្រឆាំង មួយនការ វា ជា ឃាតកម្ម ប្រឆាំងនឹង មនុស្សជាតិ។ ត្រូវដឹងថា បើស្រុកខ្មែរ មាន សង្គ្រាម អ្នក ដែល ទទួល រងគ្រោះថ្នាក់ ជា បន្ទាន់ គឺ លោក ហ៊ុន សែន តែម្តង ព្រោះ សង្គ្រាម គឺ មានតែគាត់ ជា ប្រកាសក:[7] វា ដូច្នេះ ជា ស ង្គ្រាម ហ៊ុនសែន នឹង ស្រមោលគាត់ ញ្ជិត ប្រជាពលរដ្ឋខ្មែរ គ្មាន អាវុធ សំរាប់ ធ្វើ សង្គ្រាម នោះឡើយ។ ដូច្នេះ បើ យើង យកសំដី លោក ហ៊ុន សែន មកពិចារណា វា មិនមែន ជា ពាក្យ កំហែង តែ ជា ពាក្យកម្លែង ទៅវិញ របស់ បុគ្គលម្នាក់ ដែល កំពុងរស់នៅ មាន សេចក្ដីភ័យខ្លាច នៅចំពោះមុខ ស្រមោល ខ្លួនឯង ជា ជនផ្តាច់ការដុះស្ពឹម ដូច ពីងពាង ជួនកាល វាឡប់ បែរជា ប្រយុទ្ធប្រឆាំងនឹងខ្លួនឯង រហូតមាន គ្រោះថ្នាក់ដល់ មរណ:។ តែចំពោះយើង មិនចង់ឃើញ ករណី លោក ហ៊ុន សែន ដូច ពីងពាង នោះទេ គឺ ចង់ឲគាត់ រស់ បានយូរអង្វែង ក្នុង ប រិបទ នៃ ការប្ដូរ និន្នាការ នយោបាយដឹកនាំ ដើម្បី ឲ គាត់អាច រិចិយ និង ប្រៀបធៀប របៀបដឹងនាំ បែប ប្រជាធិបតេ យ្យសេរី ពិតប្រាកដ នឹង ផ្តាច់ការ ថា តើ របៀប មួយណា វា មាន ប្រយោជន៏ ជាសច្ចៈប្រសើពិត ដល់ ស្រុកខ្មែរ ដែល ជា ជាតិភូមិ របស់ លោក ហ៊ុន សែន។

[7]ប្រកាសក:; អ្នកប្រកាសដំណឹង ; héraut។